# របាយការណ៍សង្ខេប

# ការអង្កេត និងការវាយតម្លៃលើការអនុវត្តកម្មវិធីនយោបាយដែលមានសូចនាករច្បាស់លាស់របស់រាជរដ្ឋាភិបាល និងមន្ត្រីជាប់ឆ្នោតនីតិកាលទី៤

ខុមហ្វ្រែល COMFREL

ផលិតដោយខុមហ្វ្រែល

ខែមិថុនា ឆ្នាំ២០១៣

# របាយការណ៍សង្ខេប ការអង្កេត និងវាយតំលៃលើការអនុវត្តន៍កម្មវិធីនយោបាយ ដែលមានសូចនាករច្បាស់លាស់របស់រាជរដ្ឋាភិបាល និងមន្ត្រីជាប់ឆ្នោតនីតិកាលទី៤នៃរដ្ឋសភា

## I. សេចក្តីផ្តើម

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល)បានអនុវត្តគម្រោងឃ្លាំមើលការអនុវត្តន៍ការសន្យារបស់រាជរដ្ឋាភិបាល តាំងពីនីតិកាលទី៣នៃរដ្ឋសភា ហើយក៏បន្តឃ្លាំមើលការអនុវត្តន៍ការសន្យារបស់រាជរដ្ឋាភិបាលអាណត្តិទី៤នេះទៀត។ ចំពោះរាជរដ្ឋាភិបាលនីតិកាលទី៤នេះ ត្រូវបានបង្កើតឡើងនៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ដោយរលូនក្រោមការបោះឆ្នោតជាកញ្ចប់ ដែលជ្រើសរើសសមាជិកគណៈរដ្ឋមន្ត្រី រួមទាំងនាយករដ្ឋមន្ត្រី ប្រធាន និងអនុប្រធានរដ្ឋសភា និងប្រធាន និងអនុប្រធានគណៈកម្មការរដ្ឋសភាទាំង៩ ដោយសំលេងគាំទ្រចំនួន៩៤/៩៤ មកពីគណបក្សប្រជាជនកម្ពុជា គណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សនរោត្តម រណឫទ្ធិ។ រីឯគណបក្សសមរង្ស៊ី និងគណបក្សសិទ្ធិមនុស្សមិនបានចូលរួមក្នុងសម័យប្រជុំនោះឡើយ។

បើទោះបីជារាជរដ្ឋាភិបាលអាណត្តិទី៤ នៅបន្តកើតចេញពីចំរុះគណបក្សនយោបាយ (គណបក្សប្រជាជនកម្ពុជា និងគណបក្សហ៊្វុនស៊ិនប៉ិច)ក៏ដោយ ក៏ប៉ុន្តែជាក់ស្តែងគណបក្សប្រជាជនកម្ពុជានៅតែត្រួតត្រា និងដឹកនាំទាំងស្រុង បន្ទាប់ពីគណបក្សនេះទទួលបានអាសនៈនៅរដ្ឋសភាដ៏ច្រើនលើសលប់ ប្រមាណ៧៣% ឬស្មើនឹង៩០អាសនៈរដ្ឋសភាសរុប។ រាជរដ្ឋាភិបាលអាណត្តិទី៤នេះ មានចំនួនមន្ត្រីនយោបាយ (សមាជិកគណៈរដ្ឋមន្ត្រី)ច្រើនជាងអាណត្តិមុនៗ គឺមានជាសរុបចំនួន២៤៩រូប([1])។

នៅពេលចូលកាន់តំណែង នាយករដ្ឋមន្ត្រីបានប្រកាសដាក់ចេញជាផ្លូវការនូវកម្មវិធីនយោបាយរបស់ខ្លួនចំនួន៤៨([2])ចំណុច ដែលមានការសន្យាជាច្រើនទៀត នៅក្នុងចំណុចនីមួយៗនៃកម្មវិធីនយោបាយ រួមទាំងការអនុវត្តន៍កំណែទម្រង់វិស័យធំៗឱ្យស៊ីជម្រៅទៀតផង។ ដើម្បីអនុវត្តគោលនយោបាយនេះ រាជរដ្ឋាភិបាលក៏បានបន្តអនុវត្តយុទ្ធសាស្រ្តចតុកោណជំហានទី២ ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធិភាពនៅកម្ពុជា។ ដើម្បីបង្កើនតម្លាភាព និងជំរុញឱ្យរាជរដ្ឋាភិបាលមានការទទួលខុសត្រូវនូវអ្វីដែលខ្លួនបានសន្យា ខុមហ្វ្រែលបានធ្វើការអង្កេត និងលើកទឹកចិត្តឱ្យម្ចាស់ឆ្នោតវាយតម្លៃលើការអនុវត្តន៍

([1])ទិន្នន័យនេះបានកមពីការគណនាចំនួនសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាផ្សព្វផ្សាយនៅក្នុងវ៉េបសាយ របស់ទីស្តីការគណៈរដ្ឋមន្ត្រី៖ http://www.pressocm.gov.kh/khmer/govhierachy.php ឬសូមមើល៖
http://www.cambodiamirror.org/2008/09/27/friday-2692008-the-fourth-term-government-has-250-members-without-calculating-the-number-of-under-secretaries-of-state/

([2]) សូមមើល កម្មវិធីនយោបាយនយោបាយរបស់រាជរដ្ឋាភិបាលនៃនីតិកាលទី៤នៃរដ្ឋសភា (ភ្នំពេញ ខែកញ្ញា ឆ្នាំ២០០៨)

កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល។

ទោះបីជាយ៉ាងណាក៏ដោយ ការសន្យា ក៏ដូចជាកម្មវិធីនយោបាយភាគច្រើនរបស់រាជរដ្ឋាភិបាល មានលក្ខណៈទូលំទូលាយ និងជាពិសេសមិនមានសូចនាករច្បាស់លាស់ ដែលជាហេតុនាំឱ្យពិបាកក្នុងការតាមដាន ថាតើការសន្យានោះសំរេចបានកំរិតណា។ ខុមហ្វ្រែលនឹងរៀបចំទម្រង់វាយតម្លៃដាក់ពិន្ទុដោយឡែកទៅលើចំណុចនៃកម្មវិធីនយោបាយដែលគ្មានសន្ទស្សន៍ដោយម្ចាស់ឆ្នោត។

ការអង្កេតរបស់ខុមហ្វ្រែលផ្តោតទៅលើតែកម្មវិធីនយោបាយ ដែលមានសូចនាករ ឬលក្ខណៈសន្ទស្សន៍ច្បាស់លាស់តែប៉ុណ្ណោះ។ ការអង្កេតរបស់ខុមហ្វ្រែលទៅលើកម្មវិធីនយោបាយមាននៅក្នុងផ្នែកទី៣។

## II. ទំហំរបាយការណ៍ និងវិធីសាស្ត្រនៃការអង្កេត

វិធីសាស្ត្រ គឺនិយាយបានទៅដល់ការអង្កេត និងការវាយតំលៃទៅលើកម្មវិធីនយោបាយដែលមាន ឬបានកំណត់សូចនាករច្បាស់លាស់ ឬលក្ខខណ្ឌសន្ទស្សន៍ដែលអាចវាស់វែងបានដែលមាននៅក្នុងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៤ប៉ុណ្ណោះ។

ការសន្យាដែលមានសូចនាករច្បាស់លាស់ ត្រូវបានកំណត់ថា ជាការសន្យាមួយដែលមានលទ្ធផលជាក់ស្តែងអាចវាស់វែងបាន ដូចជាការអនុម័តការបង្កើតស្ថាប័ន ឬជាសកម្មភាពការអនុវត្តអ្វីមួយច្បាស់លាស់ដោយមានគោលដៅពេលវេលា ឬមានចំនួនកំណត់ច្បាស់លាស់ ឬមួយប្រៀបធៀបទៅនឹងអត្រាណាមួយច្បាស់លាស់។

ក្នុងន័យនេះ ខុមហ្វ្រែលបានសិក្សា និងបានរកឃើញការសន្យានៅក្នុងកម្មវិធីនយោបាយ៤៨ចំណុចដែលមានសូចនាករច្បាស់លាស់បានត្រឹមតែចំនួន១០ចំណុចដូចដែលបានរៀបរាប់ខាងក្រោម។

ការសន្យាដែលនឹងលើកយកមកបកស្រាយក្នុងរបាយការណ៍នេះ គឺសំដៅទៅដល់ការសន្យាដែលមានសូចនាករច្បាស់លាស់។ ការកំណត់សូចនាករនេះទៀតសោត គឺនិយាយទាក់ទងទៅនឹងការសន្យា «បង្កើត ឬផ្តល់ ឬបង្កើនអ្វីមួយ» ដោយបានបង្ហាញចំនួន ឬប្រៀបធៀបអ្វីមួយជាក់លាក់។

ការអង្កេតវិភាគនេះ គឺសិក្សាតែលើការសន្យាណាដែលមានសូចនាករច្បាស់លាស់តែប៉ុណ្ណោះ។ ដោយឡែក ការប្រមូលព័ត៌មានដែលទាក់ទងទៅនឹងការសន្យាដែលមានសូចនាករច្បាស់លាស់នេះ គឺខុមហ្វ្រែលពឹងលើទិន្នន័យដែលមានស្រាប់ ដូចជាប្រព័ន្ធផ្សព្វផ្សាយ របាយការណ៍របស់ក្រសួង និងស្ថាប័ននានា និងរបស់អង្គការ ឬស្ថាប័នអន្តរជាតិនានា។

***ការសង្ខេបការសន្យាដែលមានសូចនាករច្បាស់លាស់រួមមាន៖***

១. រាជរដ្ឋាភិបាល...ខិតខំសំរេចនូវកំណើនសេដ្ឋកិច្ចពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១៣ ឱ្យបានជាមធ្យម ៧%ក្នុងមួយឆ្នាំ។

២. រាជរដ្ឋាភិបាលនឹងខិតខំបង្កើនផលិតផលសរុបសម្រាប់មនុស្សម្នាក់ ឲ្យកើនឡើងដល់ចំនួនប្រមាណ៨៧០ដុល្លារអាមេរិកក្នុងឆ្នាំ២០១៣។

៣. រាជរដ្ឋាភិបាល... កាត់បន្ថយភាពក្រីក្ររបស់ប្រជាជនឲ្យបានជាមធ្យមលើសពី១%ក្នុងមួយឆ្នាំ។

៤. រាជរដ្ឋាភិបាល...បង្កើនប្រាក់បៀវត្សរ៍ជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធឲ្យបានយ៉ាងតិច ២០% ក្នុងមួយឆ្នាំលើប្រាក់បៀវត្សរ៍មូលដ្ឋាន។

៥. បង្កើនផ្ទៃដីដោះមីនឲ្យដល់៤៥,000 ហិកតានៅឆ្នាំ២០១០។

៦. រាជរដ្ឋាភិបាលបន្តអភិវឌ្ឍន៍សមត្ថភាពផ្គត់ផ្គង់ទឹកស្អាត... ដោយខិតខំសម្រេចទិសដៅផ្គត់ផ្គង់ទឹកស្អាតដល់ប្រជាជននៅជនបទឲ្យបានពី៤០ ទៅ៤៥% នៅឆ្នាំ២០១២។

៧. រាជរដ្ឋាភិបាល...ខិតខំរក្សាកំណើនភ្ញៀវទេសចរបរទេសប្រមាណ២០%ជារៀងរាល់ឆ្នាំ។

៨. រាជរដ្ឋាភិបាល...ជំរុញឲ្យកុមារទូទៅបញ្ចប់ការសិក្សាថ្នាក់បឋមសិក្សានៅឆ្នាំ២០១០...។

៩. រាជរដ្ឋាភិបាល...ជំរុញឲ្យកុមារទូទៅបញ្ចប់ការសិក្សាកម្រិតមូលដ្ឋាន៩ឆ្នាំ នៅឆ្នាំ២០១៥...។

១០. រាជរដ្ឋាភិបាលនឹងរៀបចំបង្កើតប្រព័ន្ធសន្តិសុខសង្គម សម្រាប់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ កម្មករ និងនិយោជិត និងស្រទាប់ប្រជាជនផ្សេងៗ...។

## III.លទ្ធផលការអង្កេតការអនុវត្តន៍កម្មវិធីនយោបាយ ដែលមានសូចនាករច្បាស់លាស់

### ១. *«រាជរដ្ឋាភិបាល...ខិតខំសំរេចនូវកំណើនសេដ្ឋកិច្ច ពីឆ្នាំ២០០៨ ដល់២០១៣ ឱ្យបានជាមធ្យម៧% ក្នុងមួយឆ្នាំ»* ។

ការសន្យានេះស្ថិតនៅក្នុង និងជាផ្នែកទី២([3])(វិស័យសេដ្ឋកិច្ច) នៃចំណុចទី១៦ នៃកម្មវិធីគោលនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៤។

សំរាប់កំណើនសេដ្ឋកិច្ចដែលរាជរដ្ឋាភិបាលបានសន្យា ដោយខិតខំសំរេចនូវកំណើនសេដ្ឋកិច្ចពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១៣ ឲ្យបានជាមធ្យម៧%ក្នុងមួយឆ្នាំ ត្រូវបានសង្កេតឃើញថា រាជរដ្ឋាភិបាលមិនបានសម្រេចទាំងស្រុងនូវការសន្យានេះទេសំរាប់ឆ្នាំ២០១១ និងឆ្នាំ២០១២។

([3]) កម្មវិធីនយោបាយនយោបាយរបស់រាជរដ្ឋាភិបាលនៃនីតិកាលទី៤នៃរដ្ឋសភា (ភ្នំពេញ ខែកញ្ញា ឆ្នាំ២០០៨) ទំព័រ៦

ប្រសិនបើសង្កេតមើលលើកំណើនសេដ្ឋកិច្ចឆ្នាំ២០១១ ប្រទេសកម្ពុជាមានកំណើនសេដ្ឋកិច្ច ៦,៨% នេះ បើយោងតាមរបាយការណ៍របស់ធនាគារអភិវឌ្ឍន៍អាស៊ីនៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១១ ([4])។ យោងតាមរបាយការណ៍ក្រសួងផែនការវិញបានបង្ហាញថា ប្រទេសកម្ពុជាមានកំណើនសេដ្ឋកិច្ច ៦,៩% ក្នុងឆ្នាំ២០១១ និង៦,៥%ក្នុងឆ្នាំ២០១២([5])។ ដូចគ្នាដែរ បើយោងតាមធនាគារពិភពលោកក្នុងឆ្នាំ២០១១ កម្ពុជាមានកំណើនសេដ្ឋកិច្ចប្រហែល៧%(៦,៩%)([6])។ បើទោះបីជារាជរដ្ឋាភិបាលមិនទាន់បានសម្រេចទាំងស្រុងដូចការសន្យាក៏ដោយ ក៏វាជាកំណើនមួយគួរឱ្យកត់សម្គាល់ ខណៈដែលឆ្នាំ ២០១១ ប្រទេសកម្ពុជាកំពុងតែជួបបញ្ហាគ្រោះទឹកជំនន់។

តាមរបាយការណ៍របស់ធនាគារពិភពលោកដដែលបានឱ្យដឹងថា កំណើនសេដ្ឋកិច្ចប្រចាំឆ្នាំ ២០១២ គឺមានតែប្រមាណ៦,៦%([7])ប៉ុណ្ណោះ។ ប្រហាក់ប្រហែលគ្នានេះដែរ បើយោងតាមទិន្នន័យរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានបង្ហាញថា កំណើនសេដ្ឋកិច្ចមានតែប្រមាណ៦,៥%([8])នៅឆ្នាំ២០១២នេះ។ កំណើនសេដ្ឋកិច្ចនេះ បណ្តាលមកពីការកើនឡើងនៃការនាំចេញសម្លៀកបំពាក់ កំណើននាំចេញវិស័យកសិកម្ម កំណើនភ្ញៀវទេសចរ ការស្ទុះឡើងវិស័យអចលនទ្រព្យ និងការកើនឡើងនៃការនាំអង្ករចេញទៅក្រៅប្រទេស។ បើតាមស្ថិតិរបស់វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា សម្រាប់ឆ្នាំ ២០១២ កំណើនសេដ្ឋកិច្ចកម្ពុជាមានប្រមាណជា៦,២%([9])។

មានលក្ខណៈខុសគ្នាចំពោះស្ថិតិប៉ាន់ប្រមាណរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ([10]) បានបង្ហាញថា កំណើនសេដ្ឋកិច្ចកម្ពុជាសម្រេចបាន ៧,១%នៅឆ្នាំ២០១១ ហើយនឹងអាចសម្រេចបានក្នុងរង្វង់ប្រមាណជា៧%នៅឆ្នាំ២០១២នេះ។ តាមការអះអាងរបស់ក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ កំណើនសេដ្ឋកិច្ចបានមកពីកត្តាសំខាន់ៗដូចជា៖ កំណើននៃវិស័យកសិកម្មភាគច្រើន ដោយសារការបន្តកើនឡើងនៃដំណាំស្រូវ កៅស៊ូ និងបណ្តាដំណាំដែលកំពុងមានសក្តានុពលនៅលើទីផ្សារដទៃទៀត ដូចជាពោត

---

([4]) ADB Lifts Cambodia's 2011 Growth, But Global Market Concerns Remain for 2012: http://www.adb.org/news/cambodia/adb-lifts-cambodias-2011-growth-global-market-concerns-remain-2012

([5]) ក្រសួងផែនការ៖ របាយការណ៍វឌ្ឍនភាព ស្តីពីការអនុវត្តន៍ផ.យ.អ.ជ.បច្ចុប្បន្នកម្ម ២០០៩-២០១៣ ដោយពិនិត្យមើលពីវឌ្ឍនភាពផ្នែកសង្គម រួមទាំងការសម្រេចបាន គ.អ.ស.ក. ឆ្នាំ២០១២ (ភ្នំពេញ ខែធ្នូ ឆ្នាំ២០១២)

([6]) WORLD BANK EAST ASIA AND PACIFIC ECONOMIC UPDATE 2012, VOLUME 1: *Capturing New Sources of Growth* (May 2012).P.44

([7])សារព័ត៌មាន ឌឺខេមបូឌាដេលី៖ World Bank Foresees 6.7% Growth in 2013។ ផ្សាយចេញថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៣

([8]) IMF Country Report No.12/46: CAMBODIA: STAFF REPORT FOR THE 2011 ARTICLE IV CONSULTATION (January 18, 2012). P.3

([9]) វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា៖ វ.ស.ក រក្សាការព្យាករណ៍កំណើនសេដ្ឋកិច្ចដដែលត្រឹមអត្រា៦,២%សម្រាប់ឆ្នាំ២០១២: http://www.eicambodia.org/events/upfile/CEW15EIC-ETM-press-release-120718-KH-38.pdf

(10) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូចនាករម៉ាក្រូសេដ្ឋកិច្ច។ http://www.mef.gov.kh/

សណ្តែក និងដំឡូងមីជាដើម។ វិស័យឧស្សាហកម្មមានការរីកលូតលាស់ដោយការបន្តកើនឡើងនៃផ្នែកវាយនភ័ណ្ឌ ការកែច្នៃ សំណង់ និងអគ្គិសនី និងកំណើននៃវិស័យសេវាកម្ម គឺភាគច្រើនបានមកពីការបន្តមានកំណើននៃវិស័យទេសចរណ៍ ហិរញ្ញវត្ថុ និងធនាគារ អចលនវត្ថុ ពាណិជ្ជកម្ម ព្រមទាំងការដឹកជញ្ជូន និងទូរគមនាគមន៍។ ចំពោះក្រសួងផែនការវិញ ប្រទេសកម្ពុជាមានកំណើនសេដ្ឋកិច្ច៦,៥% ក្នុងឆ្នាំ២០១២([11])។

គួររំឭកថា សំរាប់ឆ្នាំ២០០៩ និងឆ្នាំ២០១០ រាជរដ្ឋាភិបាលក៏មិនបានសំរេចទាំងស្រុងចំពោះកំណើនសេដ្ឋកិច្ចដែលបានសន្យាឲ្យដល់៧%ក្នុងមួយឆ្នាំដែរ។

បើយោងតាមព័ត៌មានពីស្ថាប័ន**ស៊ី អាយ អេ** (CIA)([12]) របស់សហរដ្ឋអាមេរិក កំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជានៅឆ្នាំ២០១១បានមកពី៖ ៣៤,៦%មកវិស័យកសិកម្ម ២៤,១%បានមកពីវិស័យឧស្សាហកម្ម និង៤១,៣%បានមកពីវិស័យសេវាកម្ម។ ក្នុងន័យដូចគ្នា ប្រសិនបើក្រឡេកមើលប្រភពនៃកំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា តាមរយៈហិរញ្ញវត្ថុសកលនៅឆ្នាំ២០១១([13]) បានឲ្យដឹងថា ៣០,៩%នៃកំណើនសេដ្ឋកិច្ចបានមកពីវិស័យកសិកម្ម ២២%បានមកពីវិស័យឧស្សាហកម្ម និង៤០% បានមកពីវិស័យសេវាកម្ម។

ជាសរុប យោងតាមតួលេខកំណើនសេដ្ឋកិច្ចខាងលើរបស់ស្ថាប័ននានា ដែលធ្វើការប៉ាន់ប្រមាណរាជរដ្ឋាភិបាលពុំទាន់បានសម្រេចការសន្យាទាំងស្រុង ក្នុងការជំរុញកំណើនសេដ្ឋកិច្ចដូចអ្វីដែលបានសន្យានៅក្នុងនីតិកាលទី៤នៅឡើយទេ។ ក៏ប៉ុន្តែ ថ្វីបើមានកំណើនសេដ្ឋកិច្ចប្រហាក់ប្រហែល៧%ក៏ពិតមែន តែមានអ្នកវិភាគបញ្ហាសង្គម និងសេដ្ឋកិច្ចបានរិះគន់ថា កំណើនសេដ្ឋកិច្ចនេះមិនបានឆ្លុះបញ្ចាំងពីជីវភាពរស់នៅបច្ចុប្បន្នរបស់ប្រជាជនភាគច្រើន ដែលរងគ្រោះពីបញ្ហាអត់ការងារធ្វើ ទំនិញឡើងថ្លៃ និងចំណាកស្រុកនោះទេ ហើយកំណើនសេដ្ឋកិច្ចនេះបានមកពីតែក្រុមមនុស្សមួយចំនួនតូច ដែលមានកម្រិតជីវភាពធូរធារខ្ពស់ដាច់ឆ្ងាយពីប្រជាជនភាគច្រើនទូទៅ([14])។

## ២. ***«រាជរដ្ឋាភិបាលនឹងខិតខំបង្កើនផលិតផលសរុបសំរាប់មនុស្សម្នាក់ ឱ្យកើនឡើងដល់ចំនួនប្រមាណ៨៧០ដុល្លារក្នុងឆ្នាំ២០១៣»***។

---

([11]) ក្រសួងផែនការ *ដ.ឯ.ម* ទំព័រ៨

([12]) គេហទំព័រ ស៊ី អាយ អេ៖ CIA: https://www.cia.gov/library/publications/the-world-factbook/geos/cb.html)

(13) Global Finance GDP composition by sector: http://www.gfmag.com/gdp-data-country-reports/306-cambodia-gdp-country-report.html#axzz2JQo80c00

([14]) គេហទំព័រវិទ្យុខ្មែរប៉ុស្តិ៍ផ្សាយនៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៣

http://www.thekhmerpost.com/Podcast/?p=episode&name=2013-01-26_kpr_news_2013_01_26.mp3

ការសន្យានេះ ស្ថិតនៅក្នុង និងជាផ្នែកមួយនៃចំណុចទី១៦នៃកម្មវិធីគោលនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៤។

តាមទិន្នន័យរបស់អាស៊ាន ក្នុងឆ្នាំ២០០៨ កម្ពុជាទទួលបានផលិតផលក្នុងស្រុកសម្រាប់មនុស្សម្នាក់ ប្រមាណ៨២៦ដុល្លារអាមេរិក ប៉ុន្តែចំនួននេះបានធ្លាក់ចុះមកត្រឹមប្រមាណ៧៣៥ដុល្លារអាមេរិកក្នុងឆ្នាំ២០០៩ និងប្រមាណ៧៨៥ដុល្លារអាមេរិកក្នុងឆ្នាំ២០១០។ ដោយឡែកក្នុងឆ្នាំ២០១១ កម្ពុជាសម្រេចបានកំណើនឡើងវិញ គឺផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់ កើនឡើងដល់ប្រមាណ៨៧៩ដុល្លារអាមេរិក([15])។

យោងតាមរបាយការណ៍វឌ្ឍនភាពរបស់ក្រសួងផែនការបានបង្ហាញថា នៅឆ្នាំ២០១២ ប្រជាជនកម្ពុជាទទួលបានផលទុនសរុបសម្រាប់មនុស្សម្នាក់៩៣១ដុល្លារអាមេរិក([16])។ ផលិតផលសរុបសំរាប់មនុស្សម្នាក់មាន៨៥៣ដុល្លារអាមេរិក([17]) សម្រាប់ឆ្នាំ២០១១នេះ និងឆ្នាំ២០១២ឡើងដល់៩៣៤ដុល្លារអាមេរិក([18]) បើយោងតាមរបាយការណ៍សេដ្ឋកិច្ចរបស់ World Data Atlas។

ចំពោះការប៉ាន់ប្រមាណទុករបស់វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា([19]) ផលិតផលសរុបសម្រាប់មនុស្សម្នាក់ ឆ្នាំ២០១២នឹងមានការកើនឡើងរហូតទៅដល់៩៤៥ដុល្លារ ហើយនៅឆ្នាំ២០១៣នឹងកើនរហូតដល់១០២៤ដុល្លារ សំរាប់ប្រជាពលរដ្ឋកម្ពុជាម្នាក់ៗ។ រាជរដ្ឋាភិបាលកម្ពុជាបានរក្សាអតិផរណាជាមធ្យម៥%ក្នុងមួយឆ្នាំ។ ប៉ុន្តែអតិផរណាបានកើនឡើងខ្លាំងនៅឆ្នាំ២០០៨ រហូតដល់១៩,៧% ហើយធ្លាក់ចុះមកវិញនៅឆ្នាំ២០០៩([20])។

ការប៉ាន់ប្រមាណទុករបស់វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជានេះ ខ្ពស់បន្តិចជាងការលើកឡើងរបស់លោកនាយករដ្ឋមន្ត្រីថា តាមរយៈកំណើនសេដ្ឋកិច្ច ប្រជាជនកម្ពុជាម្នាក់ៗនឹងទទួលបានផលិតផលសរុបប្រមាណ១០០០ដុល្លារ([21]) ក្នុងឆ្នាំ២០១៣។ ដូចនេះការសន្យារបស់រាជរដ្ឋាភិបាលថា នឹងខិតខំបង្កើនផលិតផលសរុប សំរាប់មនុស្សឱ្យកើនឡើងដល់ចំនួនប្រមាណ៨៧០ដុល្លារក្នុងឆ្នាំ២០១៣ នឹងអាចសម្រេចបានតាមគោលដៅពិតប្រាកដមែន។ រាជរដ្ឋាភិបាលមានទុនបំរុងជាតិ៦១០០លាន ក្នុងឆ្នាំ

---

([15]) See: http://www.asean.org/news/item/macroeconomic-indicators

([16]) ក្រសួងផែនការ *វ.ជ.ម* ទំព័រ៩

([17]) World Data Atlas: http://knoema.com/atlas/ranks/GDP-per-capita

([18]) http://knoema.com/atlas/Cambodia/GDP-per-capita

([19]) ការប៉ាន់ប្រមាណទុករបស់វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា http://www.eicambodia.org/

[20]See: http://www.asean.org/news/item/macroeconomic-indicators

([21])ការប៉ាន់ប្រមាណរបស់នាយករដ្ឋមន្ត្រីៈ http://big5.xinhuanet.com/gate/big5/news.xinhuanet.com/english/business/2012-01/24/c_131375737.htm

២០០៨ ហើយកើនឡើងដល់១០,៦៥១លានក្នុងឆ្នាំ២០១១([22])។

ជាសរុបក្នុងឆ្នាំ២០១១ និងឆ្នាំ២០១២នេះ រាជរដ្ឋាភិបាលបានសម្រេចទាំងស្រុងមុនផែនការកំណត់ ចំពោះការសន្យាថានឹងសំរេចឲ្យបានផលិតផលសរុបសម្រាប់មនុស្សម្នាក់ឲ្យឡើងដល់ចំនួនប្រមាណ៨៧០ដុល្លារ ក្នុងឆ្នាំ២០១៣។

៣.«*រាជរដ្ឋាភិបាល...កាត់បន្ថយភាពក្រីក្ររបស់ប្រជាជនឲ្យបានជាមធ្យមលើសពី១% ក្នុងមួយឆ្នាំ*»។

ការសន្យានេះស្ថិតនៅក្នុង និងជាផ្នែកនៃចំណុចទី១៦នៃកម្មវិធីគោលនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៤។

យោងតាមការបូកសរុបការងាររបស់ក្រសួងព័ត៌មាន នៅដើមឆ្នាំ២០១៣បានឱ្យដឹងថា អត្រាភាពក្រីក្របានធ្លាក់ចុះពី២២,៩%ក្នុងឆ្នាំ២០០៩ ធ្លាក់មកនៅរង្វង់២០%នៅឆ្នាំ២០១២ ហើយរំពឹងថានឹងចុះមកត្រឹម១៩%នៅឆ្នាំ២០១៣([23])។ តួលេខនេះមានលក្ខណៈផ្ទុយគ្នាទៅនឹងតួលេខដែលបានលើកឡើងរបស់សុន្ទរកថារបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន នៅក្នុងវេទិកាសន្ទនានៃបណ្តាញទំនាក់ទំនងអាស៊ីឆ្នាំ២០១០ ស្តីពី «កម្ពុជា អាស៊ាន អូស្ត្រាលី ក្រោមប្រធានបទធ្វើការរួមគ្នាដើម្បីសន្តិភាព សន្តិសុខ និងវិបុលភាពក្នុងតំបន់ និងសុខុមាលភាពប្រជាជនយើង» ដោយបានលើកឡើងថា អត្រាភាពក្រីក្រធ្លាក់មកត្រឹម២៧,៤% នៅឆ្នាំ២០០៩។

ប៉ុន្តែយ៉ាងណាមិញ តាមរបាយការណ៍ក្រសួងផែនការនៅឆ្នាំ២០១១ អត្រាភាពក្រីក្រមាន ២៤,៥% ហើយបានធ្លាក់ចុះមកត្រឹម២២.៧%នៅឆ្នាំ២០១២([24])។ ប៉ុន្តែតាមការចុះផ្សាយរបស់កាសែត ស៊ិន ហួរ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៣ លោកនាយករដ្ឋមន្ត្រីកម្ពុជាមានប្រសាសន៍ថា អត្រានៃភាពក្រីក្ររបស់កម្ពុជាធ្លាក់ចុះមកត្រឹម២០% ក្នុងឆ្នាំ២០១២ និង១៩%ក្នុងឆ្នាំ២០១៣([25])។

ជាសរុប រាជរដ្ឋាភិបាលសម្រេចបានទាំងស្រុង ក្នុងការកាត់បន្ថយភាពក្រីក្រជូនប្រជាពលរដ្ឋឲ្យបានជាមធ្យមលើសពី១%ក្នុងមួយឆ្នាំ។

៤. «*ការបង្កើនប្រាក់បៀវត្សរ៍ជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធឱ្យបានយ៉ាងតិច២០%ក្នុងមួយឆ្នាំលើប្រាក់បៀវត្សរ៍មូលដ្ឋាន*»។

---

([22]) http://www.asean.org/news/item/macroeconomic-indicators

([23]) អាត្រាភាពក្រីក្រ កម្ពុជា នឹងធ្លាក់ចុះមកត្រឹម ១៩% នៅឆ្នាំ២០១៣៖ http://www.dap-news.com/2011-06-14-02-39-55/58485-2013-02-27-04-19-53.html#sthash.GtfH3ojK.k9N2PLjJ.dpuf

([24])របាយការណ៏ក្រសួងផែនការណ៍ខែកក្កដា២០១២៖ http://www.un.org.kh/undp/media/files/Poverty%20Scorecards%20Update%202012_Eng.pdf

([25]) http://big5.xinhuanet.com/gate/big5/news.xinhuanet.com/english/business/2013-02/20/c_132180432.htm

ការសន្យានេះស្ថិតនៅក្នុង និងជាផ្នែកនៃចំណុចទី១៧ នៃកម្មវិធីគោលនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៤។ ក្នុងឆ្នាំ២០១១ និងឆ្នាំ២០១២នេះ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចទាំងស្រុងពោលគឺ បានបង្កើនប្រាក់បៀវត្សរ៍ជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធចំនួន២០% ក្នុងរយៈពេលមួយឆ្នាំលើប្រាក់បៀវត្សរ៍មូលដ្ឋាន។

យោងតាមអនុក្រិត្យលេខ ២១អនក្របក ចុះថ្ងៃទី១៩មករា២០០៩ បានបង្ហាញពីការកែប្រែតំលៃឯកតានៃសន្ទស្សន៍ប្រាក់បៀវត្សរ៍មូលដ្ឋានមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធពីចំនួន៦០០រៀលទៅ៧២០រៀល។ សន្ទស្សន៍គឺមានន័យថា មានការកើនឡើង២០%នៃកត្តាសន្ទស្សន៍។ សូមបញ្ជាក់ថា បៀវត្សរ៍មន្ត្រីរាជការ គឺគិតតាមសន្ទស្សន៍ដោយយកសន្ទស្សន៍ដែលមន្ត្រីរាជការទទួល គុណនឹងតំលៃឯកតាសន្ទស្សន៍។ ហើយការតម្លើងនេះចូលជាធរមានចាប់ពីខែមករា២០០៩។

បើយោងតាមព្រឹត្តិប័ត្រព័ត៌មានឆ្នាំ២០១១ របស់សមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ ប្រាក់បៀវត្សរ៍សម្រាប់គ្រូបង្រៀនបឋមសិក្សាជាមធ្យម គឺប្រមាណ៦០ដុល្លារក្នុងមួយខែ គ្រូអនុវិទ្យាល័យ ឬគ្រូមធ្យមសិក្សាបឋមភូមិ៩០ដុល្លារក្នុងមួយខែ ហើយ១២០ដុល្លារក្នុងមួយខែសម្រាប់គ្រូវិទ្យាល័យក្នុងឆ្នាំ២០១១ រីឯឆ្នាំ២០១២វិញ ប្រាក់បៀវត្សរ៍គ្រូបង្រៀនបឋមសិក្សាជាមធ្យម គឺប្រមាណ៧២ដុល្លារក្នុងមួយខែ គ្រូអនុវិទ្យាល័យ ឬគ្រូមធ្យមសិក្សាបឋមភូមិ១០៨ដុល្លារក្នុងមួយខែ ហើយ១៤៤ដុល្លារក្នុងមួយខែសម្រាប់គ្រូវិទ្យាល័យ([26])។ ចំនួនប្រាក់បៀវត្សរ៍នេះត្រូវបានបន្ថែម២០% ទៅលើប្រាក់បៀវត្សរ៍គោលរួចទៅហើយ។ លោករ៉ុង ឈុន ដែលជាប្រធានសមាគមគ្រូបង្រៀនឯករាជ្យធ្លាប់បានលើកឡើងថា ការតំឡើងប្រាក់បៀវត្សរ៍២០%នេះ គឺស្មើជាមធ្យមប្រមាណ៩ដុល្លារ([27])។ នេះវាជាប្រាក់បៀវត្សរ៍ដ៏តិចតួច មិនគ្រប់គ្រាន់សម្រាប់ការរស់នៅសមរម្យ បើប្រៀបទៅនឹងតំលៃទំនិញនៅលើទីផ្សារ និងបញ្ហាអតិផរណាដែលបានកើនឡើងជារៀងរាល់ឆ្នាំ។ ជាក់ស្តែងចំពោះឆ្នាំ២០១១កន្លងទៅនេះ ប្រទេសកម្ពុជាមានអត្រាកំណើនអតិផរណាចំនួន៥,៥% នៅឆ្នាំ២០១១([28]) ហើយធ្លាក់ចុះមកត្រឹមចំនួនប្រមាណតិចជាង៣% នៅឆ្នាំ២០១២([29])នេះ។ ក្នុងន័យនេះ ការតម្លើង២០%នៃប្រាក់បៀវត្សរ៍គោលរបស់មន្ត្រីរាជការ ហាក់បីដូចជា មិនត្រូវបានធ្លាក់ដល់ដៃពួកគាត់នោះទេ ព្រោះវាកាត់កងទៅនឹងអត្រាកំណើនអតិផរណាដែលតែងតែកើនឡើងជារៀងរាល់ឆ្នាំ។ ការតម្លើង២០%នេះ សមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យបានធ្វើការ

([26]) សូមមើលៈ ព្រឹត្តិប័ត្រព័ត៌មានសមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ ឆ្នាំទី៥ លេខ៣៤ ចេញផ្សាយខែកក្កដា/សីហា ឆ្នាំ២០១១ ទំព័រ៦ ឬតាមរយៈ http://www.templenews.org/wp-content/uploads/2011/11/CITA-No-34-July-and-August-2011.pdf

([27]) Civil Servant Salary Could Increase 20 Percent: http://sideth.com/civil-servant-salary-could-increase-20-percent/

([28]) Cambodia's inflation rate holds 5.5 pct in 2011: http://news.xinhuanet.com/english/business/2012-02/02/c_131388223.htm

([29]) Cambodia's inflation rate fell to 3 per cent in 2012: http://www.phnompenhpost.com/2013020761219/Business/cambodia-s-inflation-rate-fell-to-3-per-cent-in-2012.html

សិក្សាទៅឃើញថា មានការតម្លើងតិចតួចបំផុត ដូចបញ្ជាក់ក្នុងតារាងទី១ ដូចខាងក្រោម៖

**តារាងទី១៖ ការតម្លើងប្រាក់បៀវត្សរ៍គ្រូបង្រៀនរបស់រាជរដ្ឋាភិបាលចំនួន២០%ចាប់ពីឆ្នាំ២០១២ ដល់ឆ្នាំ ២០១៥**

| | ឆ្នាំ២០១០ | ឆ្នាំ២០១១ | ឆ្នាំ២០១២ | ឆ្នាំ២០១៣ | ឆ្នាំ២០១៤ | ឆ្នាំ២០១៥ |
|---|---|---|---|---|---|---|
| បឋមសិក្សា ២០% | ៥០ដុល្លារ | ៦០ដុល្លារ | ៧២ដុល្លារ | ៨៦.៤០ដុល្លារ | ១០៣.៦៨ដុល្លារ | ១២៤.៤៦ដុល្លារ |
| មធ្យមសិក្សាបឋមភូមិ ២០% | ៧៥ដុល្លារ | ៩០ដុល្លារ | ១០៨ដុល្លារ | ១២៩.៦០ដុល្លារ | ១៥៥.៥២ដុល្លារ | ១៨៦.៦២ដុល្លារ |
| មធ្យមសិក្សាទុតិយភូមិ ២០% | ១០០ដុល្លារ | ១២០ដុល្លារ | ១៤៤ដុល្លារ | ១៧២.៨០ដុល្លារ | ២០៧.៣៦ដុល្លារ | ២៤៨.៨៣ដុល្លារ |

ទោះបីជាមានការរិះគន់ និងផ្តល់យោបល់ជាច្រើនពីអង្គការសង្គមស៊ីវិល និងគណបក្សប្រឆាំងក្នុងការតម្លើងប្រាក់បៀវត្សរ៍ដល់មន្ត្រីរាជការក៏ដោយ ក៏ប្រមុខរាជរដ្ឋាភិបាលបានប្រកាសជាសាធារណៈក្នុងពិធីបើកការដ្ឋានសាងសង់ផ្លូវជាតិលេខ៥ នៅខែតុលា ឆ្នាំ២០១២នេះថា រាជរដ្ឋាភិបាលកម្ពុជានឹងមិនអាចតម្លើងប្រាក់បៀវត្សរ៍ជូនមន្ត្រីរាជការ ដូចអ្វីដែលបានស្នើនោះទេ ព្រោះរាជរដ្ឋាភិបាលត្រូវចំណាយថវិកាជាតិជាច្រើនលើការកសាងផ្លូវ ស្ពាន ប្រព័ន្ធធារាសាស្ត្រជូនប្រជាពលរដ្ឋ([30])។

ជារួម ទោះបីជាមានការរិះគន់ជាច្រើនពីបញ្ហាប្រាក់បៀវត្សរ៍តិចតួច មិនសមរម្យទៅនឹងទំនិញលើទីផ្សារក៏ដោយ តែអ្វីដែលរាជរដ្ឋាភិបាលបានសន្យាដោយតំឡើង២០%ក្នុងមួយឆ្នាំ លើប្រាក់បៀវត្សរ៍គោលគឺបានសម្រេចទាំងស្រុងក្នុងឆ្នាំ២០១១ និងឆ្នាំ២០១២នេះ។

### ៥. «*បង្កើនផ្ទៃដីដោះមីនឱ្យបានដល់៤៥០០០ហិកតា នៅឆ្នាំ២០១០*»។

ការសន្យានេះស្ថិតនៅក្នុង និងជាផ្នែកនៃចំណុចទី២៦ នៃកម្មវិធីគោលនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៤។

យោងតាមរបាយការណ៍របស់អាជ្ញាធរមីន គិតពីឆ្នាំ១៩៩២ មកដល់ខែសីហាឆ្នាំ២០១០ ផ្ទៃដីចំនួន៦០៤គីឡូម៉ែត្រក្រឡា ដែលស្មើនឹង៦០,៤០០ហិកតា ត្រូវបានបោសសម្អាត។ គ្រាន់តែ CMAC តែមួយបានបោសសម្អាតមីននៅលើផ្ទៃដីប្រមាណ៣០,៨១២ហិកតា គិតចាប់ពីឆ្នាំ១៩៩២ ដល់ឆ្នាំ

(30) Hun Sen Says Pay Rise for Civil Servants Impossible: http://www.cambodiadaily.com/news/hun-sen-says-pay-rise-for-civil-servants-impossible-3696/

២០១០([31])។ ចាប់តាំងពីការរកកើតមកដល់ត្រឹមឆ្នាំ២០១១ CMAC បានសម្អាត និងបានរំដោះផ្ទៃដីសរុប៣៣៩គីឡូម៉ែត្រក្រឡា ដែលស្មើនឹង៣៣៩០០ហិកតា តាមរយៈការសម្អាតទាំងស្រុង និងការស្ទាបស្ទង់បច្ចេកទេស ដែលក្នុងនោះផ្ទៃដី២៥៧៨០ហិកតា ត្រូវបានសម្អាតតែក្នុងរយៈពេលដប់ឆ្នាំ (២០០១-២០១០) ប៉ុណ្ណោះ([32])។ មកដល់ត្រឹមឆ្នាំ២០១១ ផ្ទៃដីជាង៦៤៣គីឡូម៉ែត្រក្រឡាត្រូវបានសម្អាតដោយប្រតិបត្តិករ([33]) ទាំងអស់ក្នុងប្រទេសកម្ពុជា([34])។

អង្គការបោសសម្អាតមីន រួមមានមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា (CMAC), អង្គការម៉ែក (MAG([35])), អង្គការហាឡូត្រាស (HALO Trust([36])) ក៏បានរកឃើញ និងបំផ្លាញមីនប្រឆាំងមនុស្សមានចំនួនជាង៨០៩០០០គ្រាប់ មីនប្រឆាំងរថក្រោះចំនួន២០,៦៧២គ្រាប់ និងសំណល់ជាតិផ្ទុះពីសង្គ្រាមមានជាង២១០០០០០([37])។ អំឡុងពេលពេញពីឆ្នាំ១៩៩២ ដល់ឆ្នាំ២០១០ អង្គការCMAC បានរកឃើញ និងបានបំផ្លាញគ្រាប់មីនក្រោមដី និងគ្រាប់មីនមិនទាន់ផ្ទុះចំនួន២,០៨៩,៤៣៧គ្រាប់ ដែលក្នុងនោះរួមមាន មីនប្រឆាំងមនុស្ស៤៤២,៤៦០គ្រាប់មីនប្រឆាំងរថក្រោះ៨,៦០៦គ្រាប់ និងគ្រាប់មិនទាន់ផ្ទុះគ្រប់ប្រភេទទាំងអស់១,៦៣៨,៣៧១ រួមទាំងគ្រាប់បែកចង្កោមផងដែរ([38])។

ដោយឡែកចាប់តាំងពីឆ្នាំ១៩៧៩ មកដល់ខែកក្កដាឆ្នាំ២០១០ មានអ្នករងគ្រោះដោយសារមីនប្រមាណ៦៣,៧០៤នាក់ ទាំងយោធា និងស៊ីវិល ដែលនៅក្នុងនោះមានអ្នករងគ្រោះដោយសារមីនប្រមាណ២៤៣នាក់នៅក្នុងឆ្នាំ២០០៩([39]) ធៀបនឹងឆ្នាំ២០០៨ មានប្រមាណ២៧១នាក់([40])។ ចំណែកឯនៅឆ្នាំ២០១០ មានអ្នករងគ្រោះដោយសារមីនចំនួន២៦០នាក់([41])។

យោងតាមរបាយការណ៍ចុងឆ្នាំ២០១១ ស្តីពីការបោសសម្អាតគ្រាប់មីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះរបស់អង្គការស៊ីម៉ាក់កម្ពុជា គិតចាប់តាំងពីឆ្នាំ១៩៩២ ដល់ឆ្នាំ២០១១ អង្គការស៊ីម៉ាក់បានធ្វើការបោស

([31]) CMAC: *20 years CMAC's Achievements in Mine Action 1992-2011,* p.7

([32]) Ibid., p.5

([33]) All operators includes Royal Cambodian Armed Force(RCAF), CMAC, MAG, and HALO TRUST

([34]) CMAC, *Saving Lives and Supporting Development for Cambodia: Integrated Workplan 2012,* p.12

([35]) Mine Advisory Group (additional information visit http://www.maginternational.org/)

([36]) Hazardous Area Life-Support Organization (additional information visit http://www.hallotrust.org/)

([37]) គេហទំព័រវិទ្យុអាស៊ីសេរី៖ អ្នករងគ្រោះដោយសារមីនកើនឡើងនៅរយៈ៩ខែឆ្នាំ ២០១០ ចុះផ្សាយថ្ងៃទី២០ ខែតុលា ឆ្នាំ ២០១០

([38]) CMAC, op.cit., P.5

([39]) សារព័ត៌មានឌឺខេមបូឌាដេលី៖ Mine Clearance Work Remains Unfinished ចុះផ្សាយថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ ២០១០

([40]) សារព័ត៌មានឌឺខេមបូឌាដេលី៖ Mine Awareness Day Brought to Cambodia's Far corners ចុះផ្សាយថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ ២០១០

([41]) សារព័ត៌មានឌឺខេមបូឌាដេលី៖ ចំនួនអ្នកស្លាប់ និងរបួសដោយយុទ្ធភណ្ឌមិនទាន់ផ្ទុះនៅឆ្នាំ២០១០ កើនលើសកាលពីឆ្នាំមុនចុះផ្សាយថ្ងៃទី១៤ ខែធ្នូ ឆ្នាំ ២០១០

សម្អាតផ្ទៃដី ដែលមានគ្រាប់មីនមិនទាន់ផ្ទុះបានចំនួនប្រមាណ១៨៣.១៩៦ហិកតា ហើយបានរុករកឃើញ និងបានកម្ទេចចោលគ្រាប់មីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះជាង២,២លានគ្រាប់។ ការសម្រេចនេះបានធ្វើឡើងក្រោមការអន្តរាគមន៍ចំនួន៦១.២៥៥ករណី។ អាជ្ញាធរមីន និងប្រតិបត្តិករទាំងអស់បានធ្វើការវាយតម្លៃឲ្យដឹងថា កម្ពុជានៅមានផ្ទៃដីដែលមានមីននៅសល់ប្រមាណជាង៦៧០គីឡូម៉ែត្រក្រឡា និងផ្ទៃដីដែលសង្ស័យថា មានមីនប្រមាណ១០៨៥គីឡូម៉ែត្រក្រឡាទៀត ដែលចាំបាច់ត្រូវធ្វើការបោសសម្អាត។ ក្នុងអំឡុងពេល៧ឆ្នាំ ពោលគឺចាប់ពីឆ្នាំ២០០០ ដល់ឆ្នាំ២០០៧ ប្រទេសកម្ពុជាមានអ្នកគ្រោះថ្នាក់ដោយសារគ្រាប់មីនប្រមាណ៨០០នាក់ក្នុងមួយឆ្នាំៗ ហើយ៣ឆ្នាំចុងក្រោយនេះ ពោលគឺចាប់ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១១ ប្រជាជនកម្ពុជាប្រមាណ៣០០នាក់ បានរងគ្រោះដោយសារគ្រាប់មីន([42])។

## តារាងទី២៖ វឌ្ឍនភាពក្នុងការបោសសម្អាតមីន

| វឌ្ឍនភាពក្នុងការបោសសម្អាតមីន | | | | | | | |
|---|---|---|---|---|---|---|---|
| សូចនាករ | ឯកតា | ឆ្នាំ២០០៨ | ឆ្នាំ២០០៩ | ឆ្នាំ ២០១០ | ឆ្នាំ២០១១ | ២០១៣ (ចំណុចដៅ) | ២០១៥ (ចំណុចដៅ) |
| កម្មវិធីបោសសម្អាតមីន | | | | | | | |
| ជនរងគ្រោះដោយសារគ្រាប់មីននិងសំណល់ជាតិផ្ទុះពីសង្គ្រាមដែលមិនទាន់ផ្ទុះ(ស្លាប់/របួស) | ចំនួន | ២៧១ | ២៤៤ | ២៨៦ | ២១១ | ២០០* | ១៥០* |
| ផ្ទៃដីដែលបានបោសសម្អាតគ្រាប់មីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម | ហិកតា | ៤៧,៦៥០ | ៥៣,៧៨៧ | ៦៤,៩៦២ | ៧៨,៤៣៧ | ៧៨,៤៨០* | ៩១,៦៩៣* |
| សូចនាករបន្ថែម | | | | | | | |
| សមាមាត្រផ្ទៃដីដែលបានបោសសម្អាតគ្រាប់មីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមរួច | | ៤០ | ៤៥ | ៥៥ | ៦៦ | ៦៦* | ៧៧* |

([42]) របាយការណ៍៦ខែ (មករា-មិថុនា ២០១១) របស់មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា៖ http://www.cmac.gov.kh/userfiles/file/6months-report.pdf

ប្រភព៖ អាជ្ញាធរជាតិកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីននិងសង្គ្រោះជនពិការដោយសារមីន ***សម្គាល់:*** *(*)* ប៉ាន់ស្មាន

ជាសរុប រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចបានជោគជ័យទាំងស្រុង ក្នុងការបង្កើនផ្ទៃដីដោះមីនដែលបានសន្យានៅក្នុងកម្មវិធីនយោបាយឲ្យកើនឡើងដល់៤៥០០០ហិកតាត្រឹមឆ្នាំ២០១០នេះ។

៦. ***«រាជរដ្ឋាភិបាលបន្តអភិវឌ្ឍន៍សមត្ថភាពផ្គត់ផ្គង់ទឹកស្អាត....ដោយខិតខំសម្រេចទិសដៅផ្គត់ផ្គង់ទឹកស្អាតដល់ប្រជាជននៅជនបទឱ្យបានពី៤០ទៅ៤៥%នៅឆ្នាំ២០១២»***។

ការសន្យានេះស្ថិតនៅក្នុង និងជាផ្នែកមួយនៃចំណុចទី៣១ នៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៤។

យោងតាមព័ត៌មានរបស់ធនាគារពិភពលោកបានឱ្យដឹងថា៩០%នៃប្រជាជនរស់នៅទីក្រុងភ្នំពេញបានទទួលទឹកស្អាត និងមានសុវត្ថិភាពក្នុងរយៈពេល២៤ម៉ោងក្នុងមួយថ្ងៃ ហើយ៧ថ្ងៃក្នុងមួយសប្តាហ៍ ([43])។

តាមប្រសាសន៍របស់លោក ស៊ុយ សែម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ផ្សាយនៅចុងខែធ្នូ ឆ្នាំ២០១០បានឱ្យដឹងថា ពលរដ្ឋខ្មែរនៅទូទាំងប្រទេសមានទឹកស្អាតប្រើប្រាស់ប្រមាណ៥៨% គិតមកដល់ចុងឆ្នាំ២០១០([44])។

តាមការអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាក្នុងឆ្នាំ២០១០ ប្រជាជនកម្ពុជានៅជនបទប្រមាណ ៤០,៥%ទទួលបានទឹកស្អាតប្រើប្រាស់ និងប្រជាជននៅទីក្រុងប្រមាណ៨០,៥%ទទួលបានទឹកស្អាតប្រើប្រាស់។ ជាមួយគ្នានេះផងដែរ ពលរដ្ឋនៅជនបទ៤២,៧% បានទទួលទឹកស្អាតប្រើប្រាស់ក្នុងឆ្នាំ ២០១១ បើធៀបជាមួយពលរដ្ឋទីប្រជុំជនមានរហូតដល់៨១,១%។ ដោយឡែកពលរដ្ឋប្រមាណ ២៨,៧% ទទួលបានអនាម័យត្រឹមត្រូវនៅក្នុងឆ្នាំ២០១០នេះ ហើយកើនឡើងដល់៣៣,៤% ក្នុងឆ្នាំ ២០១១។

**តារាងទី៣៖ សមាមាត្រប្រជាជនដែលមានទឹកស្អាតប្រើប្រាស់ និងអនាម័យនៅតំបន់ជនបទ និងទីប្រជុំជន ពីឆ្នាំ២០០៩-២០១១**

| សមាមាត្រប្រជាជនដែលមានទឹកស្អាតប្រើប្រាស់ និងអនាម័យ នៅតំបន់ជនបទ និងទីប្រជុំជន ពីឆ្នាំ២០០៩-២០១១ | | | | | |
|---|---|---|---|---|---|
| ឆ្នាំ | ឯកតា | ២០០៩ | ២០១០ | ២០១១ | ២០១៥ (ចំណុចដៅ) |

([43]) របាយការណ៍របស់ធនាគាពិភពលោក៖ http://web.worldbank.org/WBSITE/EXTERNAL/COUNTRIES/EASTASIAPACIFICEXT/CAMBODIAEXTN/0,,contentMDK:22689454~menuPK:50003484~pagePK:2865066~piPK:2865079~theSitePK:293856,00.html

([44]) ពលរដ្ឋខ្មែរ ៥៨ ភាគរយនៅទូទាំងប្រទេស មានទឹកស្អាតប្រើប្រាស់៖ http://www.cen.com.kh/home/search_results

| | | | | | |
|---|---|---|---|---|---|
| ទឹកស្អាតទីប្រជុំជន | % | ៧៨,៥ | ៨០,៥ | ៨១,១ | ៨០ |
| ទឹកស្អាតជនបទ | % | ៤២,០ | ៤០,៥ | ៤២,៧ | ៥០ |
| អនាម័យទីប្រជុំជន | % | ៨៥ | ៨៦,៦ | ៨៧,៨ | ៧៤ |
| អនាម័យជនបទ | % | ២២,៩ | ២៨,៧ | ៣៣,៤ | ៣៣ |

**ប្រភព៖ អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា**

ប៉ុន្តែបើតាមរបាយការណ៍របស់ក្រសួងផែនការ ពលរដ្ឋជនបទ៤៣,៥១% ក្នុងឆ្នាំ២០១០ ទទួលបានទឹកស្អាតប្រើប្រាស់ និង២៥% ទទួលបានអនាម័យស្អាត។ ចំណែកឯឆ្នាំ២០១១វិញ ពលរដ្ឋជនបទ ៤៤,៨៩% ទទួលបានទឹកស្អាតប្រើប្រាស់ និង២៦,៥%ទទួលបានអនាម័យស្អាត([45])។ ទោះបីជាយ៉ាងនេះក៏ដោយ ប្រទេសកម្ពុជា៥០%នៃពលរដ្ឋរស់នៅជនបទមិនមានទឹកស្អាតប្រើប្រាស់នោះទេ ហើយពលរដ្ឋជាង៨លាននាក់ ដែលប្រហែល៦៦%មិនទទួលបានអនាម័យស្អាត។ មិនតែប៉ុណ្ណោះកុមារកម្ពុជាប្រមាណ២៨% នៅតាមជនបទ មិនគ្រប់ទម្ងន់ និងក្រិន ដោយសារជំងឺឆ្លង ខ្វះអនាម័យទឹកស្អាត និងខ្វះបង្គន់អនាម័យ([46])។

យោងតាមព័ត៌មានទាំងអស់ខាងលើនេះ យើងអាចសន្និដ្ឋានបានថា រាជរដ្ឋាភិបាលបានសំរេចតាមការសន្យាលើការអភិវឌ្ឍន៍សមត្ថភាពផ្គត់ផ្គង់ទឹកស្អាត ដោយបានខិតខំសម្រេចទិសដៅផ្គត់ផ្គង់ទឹកស្អាតដល់ប្រជាជននៅជនបទឱ្យបានពី៤០ ទៅ៤៥%នៅឆ្នាំ២០១២។

ជាសរុប រាជរដ្ឋាភិបាលបានសម្រេចតាមការសន្យាក្នុងការផ្គត់ផ្គង់ទឹកស្អាតដល់ប្រជាពលរដ្ឋជនបទ។

**៧. «*រាជរដ្ឋាភិបាល...ខិតខំរក្សាកំណើនភ្ញៀវទេសចរបរទេសប្រមាណ២០%ជារៀងរាល់ឆ្នាំ*»។**

ការសន្យានេះស្ថិតនៅក្នុង និងជាផ្នែកមួយនៃចំណុចទី៣៥ នៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៤។ ក្នុងឆ្នាំ២០១១ រាជរដ្ឋាភិបាលមិនបានសំរេចតាមការសន្យាដែលថា នឹងខិតខំរក្សាកំណើនភ្ញៀវទេសចរបរទេសប្រមាណ២០%ជារៀងរាល់ឆ្នាំនោះទេ។ ប៉ុន្តែនៅឆ្នាំ២០១២ រាជរដ្ឋាភិបាលបានសំរេចចំពោះការសន្យាទាំងស្រុង។

---

([45]) ក្រសួងផែនការ *ផ.ឯ.ម.* ទំព័រ ៣៥

([46]) POOR WATER AND SANITATION CONTRIBUTE TO HIGH CHILD MALNUTRITION RATES IN CAMBODIA: http://cambopedia.com/2013/03/21/poor-water-and-sanitation-contribute-to-high-child-malnutrition-rates-in-cambodia/ (accessed on April 30,2013)

ដោយឡែកនៅឆ្នាំ២០១២ រាជរដ្ឋាភិបាលបានសំរេចចំពោះការសន្យាចំពោះរាជរដ្ឋាភិបាលបាន ទាក់ទាញភ្ញៀវទេចរណ៍ចំនួន៣,៥៨លាននាក់ ដោយមានការកើនឡើងប្រមាណ២៤,៤% ប្រសិន ធៀបទៅនឹងឆ្នាំ២០១១(47)។ នៅក្នុងឆ្នាំ២០១១កន្លងទៅនេះ ប្រទេសកម្ពុជាបានទាក់ទាញភ្ញៀវទេស ចរចំនួន២,៨៨លាននាក់ ពោលគឺមានការកើនឡើងប្រមាណជា១៤,៩% បើធៀបនឹងឆ្នាំ២០១០(48)។ ក្នុងនោះ ភ្ញៀវទេសចរក្នុងតំបន់អាស៊ានមានប្រមាណ១,១០១លាននាក់ ដោយឡែកភ្ញៀវទេសចរក្រៅ តំបន់អាស៊ានមានប្រមាណ១,៧៨០នាក់ ដែលផ្តល់ចំណូលប្រមាណ១,៩១២លានដុល្លារអាមេរិក។ ក្នុងន័យនេះ នៅក្នុងឆ្នាំ២០១១ រាជរដ្ឋាភិបាលមិនបានសំរេចតាមការសន្យាដែលថា នឹងខិតខំរក្សា កំណើនភ្ញៀវទេសចរបរទេសប្រមាណ២០%ជារៀងរាល់ឆ្នាំនោះទេ។

គួរបញ្ជាក់ដែរថា ទាំងក្នុងឆ្នាំ២០១១ និងឆ្នាំ២០១២ ភ្ញៀវទេសចរបរទេសដែលបានមកទស្សនា ច្រើនជាងគេរៀបតាមលំដាប់ គឺមានជនជាតិវៀតណាម កូរ៉េ ចិន ថៃ ជប៉ុន អាមេរិក បារាំង អូស្រាលី និងម៉ាឡេស៊ី។ កំណើននៃភ្ញៀវទេសចរអន្តរជាតិនេះមកពីកត្តាមួយចំនួនដូចជា ការប្រសើរឡើងនៃ មធ្យោបាយធ្វើដំណើរ មានកំណើនប្រាក់ចំណូលរបស់ប្រជាជននៅតំបន់អាស៊ាន មានមធ្យោបាយធ្វើ ដំណើរច្រើនប្រភេទមកកាន់ប្រទេសកម្ពុជា និងបណ្តាប្រទេសជិតខាង និងមានទំនាក់ទំនងនយោបាយ ល្អជាមួយប្រទេសជាដៃគូអភិវឌ្ឍន៍(49)។ ក្រៅពីនោះក៏មានកត្តាសំខាន់ៗ ដូចជាការផ្តល់ទិដ្ឋការនៅ ពេលមកដល់ភ្ញៀវអន្តរជាតិ និងមានការផ្សព្វផ្សាយព័ត៌មានទាក់ទាញដល់ភ្ញៀវអន្តរជាតិ តាមរយៈ ទូរទស្សន៍អន្តរជាតិល្បីៗ ដូចជាស៊ីអិនអិន (CNN) ជាដើម។

ជាសរុប រាជរដ្ឋាភិបាលមិនបានសំរេចតាមការសន្យាដែលថា នឹងខិតខំរក្សាកំនើនភ្ញៀវទេសចរ បរទេសប្រមាណ២០% ជារៀងរាល់ឆ្នាំនោះទេ។

### ៨. *«រាជរដ្ឋាភិបាល....ជំរុញឱ្យកុមារទូទៅបញ្ចប់បឋមសិក្សានៅឆ្នាំនៅ២០១០»។*

ការសន្យានេះស្ថិតនៅក្នុង និងជាផ្នែកមួយនៃចំណុចទី៣៦នៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិ បាលនីតិកាលទី៤។

បើយោងតាមរបាយការណ៍ តាំងពីឆ្នាំ២០១០មក រាជរដ្ឋាភិបាលក៏មិនទាន់សម្រេចបានក្នុងការ ជំរុញឲ្យកុមារទូទៅបញ្ចប់បឋមសិក្សានៅឡើយទេ ។ តាមរបាយការណ៍ឆ្នាំ២០១២នេះ ប្រទេសកម្ពុជា

(47) Ministry of Tourism, Tourism Statistics Annual Report 2012:
http://www.tourismcambodia.org/images/mot/statistic_reports/tourism_statistics_annual_report_2012.pdf

(48) ដូចយោងលេខ ៤៧

(49) Tourism surges in Cambodia, Phnom Penh Post February 2013:
http://www.phnompenhpost.com/2013022661600/Business/tourism-surges-in-cambodia.html

មានប្រជាជនជិត១៥លាននាក់ នៅក្នុងនោះប្រជាជនក្រោមអាយុ១៤ឆ្នាំ មានប្រមាណ៣២,២% អាយុពី១៥ ទៅ៦៤ឆ្នាំមានប្រមាណ៦៤,១% និងអាយុ៦៥ឆ្នាំឡើង មានប្រមាណ៣,៨%។ អត្រាអ្នកចេះអាន និងសរសេរអក្សរមានប្រមាណ៧៣,៦%នៃចំនួនប្រជាជន ហើយក្នុងនោះអត្រាអ្នកចេះអាន និងសរសេរអក្សរជាមនុស្សប្រុសមានចំនួន៨៤,៧%([50])។

ដើម្បីធ្វើការឆ្លើយតបទៅនឹងគោលនយោបាយ និងយុទ្ធសាស្ត្រក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ក្រសួងអប់រំកម្ពុជាបានកំណត់គោលនយោបាយសំខាន់ៗចំនួន៖

- ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌
- លើកកម្ពស់គុណភាព និងប្រសិទ្ធិភាពសេវាអប់រំ
- ការអភិវឌ្ឍន៍ស្ថាប័ន និងកសាងសមត្ថភាពមន្ត្រីអប់រំសម្រាប់ធ្វើវិមជ្ឈការ

យោងតាមសូចនាករ និងចំណុចដៅរបស់ក្រសួងអប់រំ([51])៖

- *អត្រាពិតចូលរៀនថ្មីកើនពី៩១,៩% នៅឆ្នាំសិក្សា២០០៨-២០០៩ទៅ១០០% នៅឆ្នាំសិក្សា ២០១៣-២០១៤។*
- *អត្រាពិតនៃការសិក្សានៅបឋមសិក្សា កើនពី៩៤,៤%នៅឆ្នាំសិក្សា២០០៨-២០០៩ ដល់ ៩៨.0% នៅឆ្នាំ២០១៣-២០១៤។*
- *អត្រាបញ្ចប់ការសិក្សាកើនពី៨៥,៥% នៅឆ្នាំសិក្សា២០០៨-២០០៩ ដល់១០០% នៅឆ្នាំសិក្សា ២០១៣-២០១៤។*
- *អត្រាត្រួតថ្នាក់ថយចុះពី៨,៩% នៅឆ្នាំសិក្សា២០០៨-២០០៩ មកត្រឹម៥% នៅឆ្នាំសិក្សា ២០១៣-២០១៤។*
- *អត្រាបោះបង់ការសិក្សាថយចុះពី៨,៣% នៅឆ្នាំសិក្សា២០០៨-២០០៩ មកត្រឹម៥% នៅឆ្នាំសិក្សា ២០១៣-២០១៤។*
- *យ៉ាងហោចណាស់ ៧៥% នៃសាលាបឋមសិក្សាទាំងអស់នឹងជាសាលាកុមារមេត្រីនៅឆ្នាំសិក្សា ២០១៣-២០១៤។*

([50]) ព័ត៌មានរបស់គេហទំព័រ Theodora ចុះផ្សាយឆ្នាំ២០១២៖
http://www.theodora.com/wfbcurrent/cambodia/cambodia_people.html

([51]) ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការអប់រំនៅបឋមសិក្សារបស់ក្រសួងអប់រំ៖http://www.moeys.gov.kh/km/primary-education.html

យោងតាមស្ថិតិរបស់ក្រសួងអប់រំ នៅឆ្នាំ២០១១-២០១២([52]) មានសាលាបឋមសិក្សាចំនួន ៦៨៤៩ខ្នង នៅក្នុងនោះមានថ្នាក់រៀនសរុបចំនួន៥៨៥៩៤បន្ទប់ និងមាន១៤០បន្ទប់នៅក្នុងវត្តអារាម។ ចំនួនសិស្សនៅបឋមសិក្សាពីថ្នាក់ទី១ ដល់ទី៦ គឺមានចំនួន២១៤២៤៦៤នាក់ ក្នុងនោះមានសិស្សស្រីចំនួន១០២១៥៩១ នាក់ហើយនៅក្នុងចំណោមសិស្សទាំងអស់នេះ មានសិស្សចំនួន១២៧០៦៨នាក់ រៀនត្រួតថ្នាក់។ ចំនួនគ្រូបង្រៀននៅបឋមសិក្សាមានចំនួន៤៥២៩៦នាក់ និងមានបុគ្គលិកបំរើការចំនួន១១០៤៨នាក់ ដែលមិនមែនជាគ្រូបង្រៀន។

អត្រាចុះឈ្មោះចូលរៀនបឋមសិក្សាបង្ហាញថា សិស្សចុះឈ្មោះចូលរៀនសរុប៩៤,៤% ក្នុងឆ្នាំ ២០១០ ដែលក្នុងនោះសិស្សប្រុសមានចំនួន៩៤,៨% និងសិស្សស្រីមានចំនួន៩៤,០% ហើយកើនឡើងដល់៩៦% ក្នុងឆ្នាំ២០១១។ ដោយឡែកអត្រាបញ្ចប់ការសិក្សាថ្នាក់ទី៦ ក្នុងឆ្នាំ២០១១មាន ៨៥,៣% ក្នុងនោះសិស្សប្រុស៨៥,៦% សិស្សស្រី៨៥,០% ហើយកើនឡើងដល់៨៩,៧% ក្នុងឆ្នាំ ២០១១ ដែលក្នុងនោះសិស្សប្រុស៨៩,៦% សិស្សស្រី៨៩,៩% បានបញ្ចប់ការសិក្សាដោយជោគជ័យ។ ទោះបីជាយ៉ាងនេះក៏ដោយ ក៏អត្រាកំណើននេះមិនបានឆ្លើយតបទៅនឹងការសន្យារបស់រាជរដ្ឋាភិបាល ដែលថានឹងជំរុញឲ្យកុមារទូទៅបញ្ចប់បឋមសិក្សានៅឆ្នាំ២០១០ នោះឡើយ។

## តារាងទី៤៖ តារាងការអប់រំអត្រាបញ្ចប់ការសិក្សាបឋមសិក្សា

| តារាងការអប់រំ([53]) | | | | | | |
|---|---|---|---|---|---|---|
| សូចនាករ | ឯកតា | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ ប៉ាន់ស្មាន |
| អត្រាចុះឈ្មោះចូលរៀន(បឋមសិក្សា) | | | | | | |
| មនុស្ស | % | ៩៤,៤ | ៩៤,៦ | ៩៥,២ | ៩៦,០ | ៩៧,០ |
| ប្រុស | % | ៩៤,៨ | ៩៥,០ | ៩៥,៨ | ៩៦,០ | ៩៧,០ |
| ស្រី | % | ៩៤,០ | ៩៤,៦ | ៩៤,៦ | ៩៦,០ | ៩៧,០ |

([52]) ស្ថិតិនិងសូចនាករអប់រំរបស់ក្រសួងអប់រំ ២០១១-២០១២៖
http://www.moeys.gov.kh/km/primary-education/259-emis-2011-2012.html

[53]សូមមើល៖ របាយការណ៍វឌ្ឍនភាពរបស់ក្រសួងផែនការស្តីពី *ផ.យ.អ.ជ. បច្ចុប្បន្នកម្ម ២០០៩-២០១៣* ដោយពិនិត្យមើលពីវឌ្ឍនភាព ផ្នែកសង្គម សេដ្ឋកិច្ចកម្ពុជា រួមទាំងការសម្រេចបាន *គ.អ.ស.ក. ឆ្នាំ២០១២* (ភ្នំពេញ ឆ្នាំ២០១២) ទំព័រ២៦-២៧

| | | | | | | |
|---|---|---|---|---|---|---|
| អត្រាបញ្ចប់ការសិក្សាថ្នាក់ទី៦ | | | | | | |
| មនុស្ស | % | ៨៥,៦ | ៨៣,២ | ៨៥,៣ | ៨៩,៧ | ១០០ |
| ប្រុស | % | ៨៥,៤ | ៨២,៨ | ៨៥,៦ | ៨៩,៦ | ១០០ |
| ស្រី | % | ៨៥,៧ | ៨៣,៧ | ៨៥,០ | ៨៩,៩ | ១០០ |
| អត្រាបញ្ចប់បញ្ចប់ការសិក្សាថ្នាក់ទី៩ | | | | | | |
| មនុស្ស | % | ៤៩,១ | ៤៨,៧ | ៤៦,២ | ៤២,១ | |
| ប្រុស | % | ៥២,១ | ៥០,០ | ៤៩,២ | ៤២,៦ | |
| ស្រី | % | ៤៥,៩ | ៤៧,៣ | ៤៤,៣ | ៤១,៦ | |

**ប្រភព៖ក្រសួងអប់រំយុវជន និងកីឡា**

ជារួម ទោះបីជារាជរដ្ឋាភិបាលបានខិតខំបំពេញជាច្រើនចំពោះការសន្យានេះក៏ដោយ តែរាជរដ្ឋាភិបាលមិនសម្រេចទាំងស្រុងនោះទេ។ ការសន្យានេះអាចសំរេចបានទាំងស្រុងបាន លុះត្រាតែមានការធានាឲ្យកុមារដែលមានអាយុ៦ឆ្នាំទាំងអស់បានចូលសិក្សាគ្រប់ៗគ្នា ហើយបន្ទាប់មកត្រូវមានការធានាមិនឲ្យមានអត្រាបោះបង់ការសិក្សា ហើយធានាឱ្យកុមារទាំងអស់បញ្ចប់ការសិក្សានៅថ្នាក់ទី៦។

ជាសរុប រាជរដ្ឋាភិបាលមិនបានសម្រេចតាមការសន្យា ក្នុងការជំរុញឲ្យកុមារទូទៅបញ្ចប់បឋមសិក្សានៅឆ្នាំ២០១០ នៅឡើយទេ។

**៩. ការសន្យាដែលមានសូចនាករច្បាស់លាស់ទី៩៖ *«រាជរដ្ឋាភិបាល....ជំរុញឱ្យកុមារបញ្ចប់កម្រិតមូលដ្ឋាន៩ឆ្នាំនៅឆ្នាំ២០១៥»។***

ការសន្យានេះស្ថិតនៅក្នុង និងជាផ្នែកមួយនៃចំណុចទី៣៦ នៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពីការអភិវឌ្ឍន៍ធនធានមនុស្ស។

**យោងតាមសូចនាករនិងចំណុចដៅរបស់ក្រសួងអប់រំ**([54])៖

- *អត្រាពិតនៃការសិក្សានៅថ្នាក់ទី៧-៩ កើនពី៣២% នៅឆ្នាំសិក្សា២០០៩-២០១០ ដល់*

([54]) ការពង្រឹងគុណភាព និងប្រសិទ្ធិភាពនៃការអប់រំនៅមធ្យមសិក្សារបស់ក្រសួងអប់រំ៖ http://www.moeys.gov.kh/km/general-secondary-education-.html

*៥១% នៅឆ្នាំសិក្សាឆ្នាំ២០១៣-២០១៤ ។*

- *អត្រាឆ្លងភូមិសិក្សានៅថ្នាក់ទី៩-១០ កើនពី៧៣% នៅឆ្នាំសិក្សា២០០៩-២០១០ ដល់៨៥% នៅឆ្នាំសិក្សា ២០១៣-២០១៤ ។*
- *សិស្សសម្រេចបានស្តង់ដារកម្មវិធីសិក្សា មុខវិជ្ជាភាសាខ្មែរថ្នាក់ទី៩ កើនពី៦២% នៅឆ្នាំសិក្សា ២០០៩-២០១០ ដល់៨០% នៅឆ្នាំសិក្សា ២០១៣-២០១៤។*
- *សិស្សសម្រេចបានស្តង់ដារកម្មវិធីសិក្សាមុខវិជ្ជាគណិតវិទ្យាថ្នាក់ទី៩ កើនពី៣២% នៅឆ្នាំសិក្សា ២០០៩-២០១០ ដល់ ៧០% ឆ្នាំសិក្សា២០១៣-២០១៤។*

យោងតាមស្ថិតិរបស់ក្រសួងអប់រំនៅឆ្នាំ២០១១-២០១២([55]) ប្រទេសកម្ពុជាមានសាលារៀនអនុវិទ្យាល័យ(ថ្នាក់ទី៧ដល់៩) ចំនួន១១៩៦ខ្នង ដោយមានថ្នាក់រៀនចំនួនមាន៧១២៩បន្ទប់ និង៣៩បន្ទប់ទៀតនៅវត្តអារាម។ សិស្សសិក្សានៅអនុវិទ្យាល័យមានចំនួន៣០៤៤៨៤នាក់ នៅក្នុងនោះមានសិស្សស្រីចំនួន១៤៩៥៨៨នាក់។ គ្រូបង្រៀននៅថ្នាក់អនុវិទ្យាល័យមានចំនួន១៤៣៤៨នាក់ និងមាន ២៧១៧នាក់ជាបុគ្គលិកបំរើការនៅកំរិតអនុវិទ្យាល័យ។ ក្នុងឆ្នាំ២០០៨ អត្រាសិស្សឆ្លងភូមិសិក្សា ឬសិស្សបានបញ្ចប់ការសិក្សាថ្នាក់ទី៩ មាន៤៩,១% ដែលក្នុងនោះមានសិស្សប្រុសប្រមាណ៥២% និងសិស្សស្រី៤៥,៩%តែប៉ុណ្ណោះ។ ប៉ុន្តែអត្រាសិស្សបានបញ្ចប់ការសិក្សាថ្នាក់ទី៩នេះ បានធ្លាក់ចុះជារៀងរាល់ឆ្នាំគួរឲ្យព្រួយបារម្ភ។ ជាពិសេសអត្រាសិស្សបានបញ្ចប់ការសិក្សាថ្នាក់ទី៩ បានធ្លាក់ចុះពី៥០%ក្នុងឆ្នាំ២០០៩ រហូតដល់៤២,១% ក្នុងឆ្នាំ២០១១។ បន្ថែមពីលើនេះទៅទៀត ក្នុងឆ្នាំសិក្សា២០១២-២០១៣ អត្រាសិស្សឆ្លងភូមិសិក្សា ឬសិស្សបានបញ្ចប់ការសិក្សាថ្នាក់ទី៩បានធ្លាក់ចុះ គឺមានត្រឹមតែ ៤០,៦២% ដែលក្នុងនោះមាន សិស្សស្រី៤០,៣៥%តែប៉ុណ្ណោះ([56])។

## តារាងទី៥៖ តារាងអប់រំអត្រាបញ្ចប់ការសិក្សាថ្នាក់ទី៩

| តារាង ការអប់រំ | | | | | |
|---|---|---|---|---|---|
| ចំណុចដៅ/សូចនាករ | ឯកតា | ២០០៨ | ២០០៩ | ២០១០ | ២០១១ |
| អត្រាបញ្ចប់បញ្ចប់ការសិក្សាថ្នាក់ទី៩ | | | | | |

([55]) ស្ថិតិ និងសូចនាករអប់រំរបស់ក្រសួងអប់រំ ២០១១-២០១២៖ http://www.moeys.gov.kh/km/primary-education/259-emis-2011-2012.html

([56]) សន្និបាតបូកសរុបលទ្ធផលការងារ អប់រំ យុវជន និងកីឡាឆ្នាំសិក្សា២០១១-២០១២ និងលើកទិសដៅឆ្នាំសិក្សា២០១២០២០១៣ ខែមីនា ឆ្នាំ២០១៣ ទំព័រទី៤

| | | | | | |
|---|---|---|---|---|---|
| មនុស្ស | % | ៤៩.១ | ៤៨.៧ | ៤៦.២ | ៤២.១ |
| ប្រុស | % | ៥២.១ | ៥០.០ | ៤៩.២ | ៤២.៦ |
| ស្រី | % | ៤៥.៩ | ៤៧.៣ | ៤៤.៣ | ៤១.៦ |

**ប្រភព៖ ក្រសួងអប់រំយុវជននិងកីឡា**

ទោះបីជារាជរដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងយ៉ាងណាក៏ដោយ ក៏រាជរដ្ឋាភិបាលកម្ពុជាមិនទាន់បានសម្រេចដល់គោលដៅ ដែលបានសន្យាជំរុញឱ្យកុមារបញ្ចប់កម្រិតមូលដ្ឋាន៩ឆ្នាំ នៅឆ្នាំ២០១៥ ទាំងស្រុងនោះទេ។

ជាសរុប រាជរដ្ឋាភិបាលមិនបានសម្រេចតាមការសន្យាក្នុងការជំរុញឲ្យកុមារបញ្ចប់កម្រិតមូលដ្ឋាន៩ឆ្នាំ នៅឆ្នាំ២០១៥នោះទេ។

## ១០. ការសន្យាដែលមានសូចនាករច្បាស់លាស់ទី១០៖ *«រាជរដ្ឋាភិបាលនឹងរៀបចំបង្កើត ប្រព័ន្ធសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការកងកំលាំងប្រដាប់អាវុធកម្មករនិងនិយោជិតនិងស្រទាប់ប្រជាជនផ្សេងៗ។*

ការសន្យានេះស្ថិតនៅក្នុង និងជាផ្នែកមួយនៃចំណុចទី៣៨នៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៤។

រាជរដ្ឋាភិបាលបានសម្រេចបានច្រើន ក្នុងការបង្កើតជាស្ថាប័នទាក់ទងនឹងប្រព័ន្ធសន្តិសុខសង្គម ក៏ប៉ុន្តែដំណើរការនេះនៅមានភាពស្មុគស្មាញ និងការផ្តល់សេវានៅមានភាពមិនច្បាស់លាស់។ ការបង្កើតប្រព័ន្ធសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការ និងកងកំលាំងប្រដាប់អាវុធ គឺពុំទាន់ឃើញមានច្បាប់ច្បាស់លាស់នៅឡើយ បើទោះបីជាមានយន្តការអនុវត្តន៍ដោយឡែកតាមក្រសួងនីមួយៗ។

ដើម្បីអនុវត្តច្បាប់ស្តីពី របបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារត្រូវបានបង្កើតឡើងនៅឆ្នាំ២០០២។ អនុក្រិត្យ ស្តីពីបេឡាជាតិរបបសន្តិសុខសង្គម លេខ១៦អនក្រ-បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ការងារធានារ៉ាប់រងហានិភ័យការងារក៏ត្រូវបានបង្កើត។

ប្រកាសក្រសួងការងារ ស្តីពីតាវកាលិកហានិភ័យការងារក៏ត្រូវបានបង្កើតឡើងផងដែរ នៅឆ្នាំ២០០៨ ដែលកំណត់ពីសិទ្ធិទទួលបាន និងបែបបទ និងកំរិតនៃការទទួលបានតាវកាលិកហានិភ័យការងារសំរាប់គ្រឹះស្ថានដែលចុះបញ្ជីក្នុងបេឡាជាតិរបបសន្តិសុខសង្គម។

ជាបន្តបន្ទាប់ បេឡាជាតិរបបសន្តិសុខសង្គម ក្រោមការទទួលខុសត្រូវរបស់ក្រសួងការងារក៏បាន

ចេញលិខិតដាក់កំហិតដល់ស្ថាប័នសហគ្រាស ក្រុមហ៊ុន និងរោងចក្រនានា ចាប់បង្ខំឱ្យចុះបញ្ជី និងបង់វិភាគទានជាមួយបេឡាជាតិរបបសន្តិសុខសង្គម។

ជាក់ស្តែងថ្មីៗ នៅចុងឆ្នាំ២០១២([57])នេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតែងតែបានជូនដំណឹង ស្តីពីការចុះបញ្ជីការសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គមនៅទីរួមខេត្តមួយចំនួន ដូចជារតនគិរី មណ្ឌលគិរី ព្រះវិហារ ឧត្តរមានជ័យជាដើម ហើយបានដាក់កំរិតឱ្យប្រជាពលរដ្ឋនៅទីនោះចូលរួមអនុវត្តដោយស្មារតីទទួលខុសត្រូវខ្ពស់។

មូលនិធិសន្តិសុខសង្គមជាតិ ត្រូវបានបង្កើតឡើងនៅក្នុងខែមីនា ឆ្នាំ២០០៨ ដើម្បីគ្រប់គ្រងទៅលើសន្តិសុខសង្គមរបស់កម្មករវិស័យឯកជន ដែលចាប់ផ្តើមអនុវត្តជាមួយបណ្តាក្រុមហ៊ុន ដែលមានកម្មករប្រាំបីអ្នកឡើងទៅ។ មូលនិធិសន្តិសុខសង្គមជាតិ បានមកពីការរួមវិភាគទានថវិការបស់និយោជិត និងថវិការដ្ឋ។ ក្នុងឆ្នាំ២០១០ កម្មករចំនួន៤៩០០០០នាក់ទទួលបានផលប្រយោជន៍ពីសេវានេះ ដែលត្រូវជា៧០%នៃកម្មករទាំងអស់ ដែលធ្វើការនៅក្នុងសហគ្រាស ដែលមានកម្មករលើសពីប្រាំបីនាក់ ឬក៏តិចជាង១០% នៃកម្លាំងពលកម្មសរុប([58])។ មូលនិធិសន្តិសុខសង្គមជាតិសម្រាប់មន្ត្រីរាជការ (NSSF-C) ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៨ និងបានប្រតិបត្តិការពេញលេញក្នុងខែឧសភា ឆ្នាំ២០០៩ មន្ត្រីរាជការស៊ីវិល បានគ្របដណ្តប់មន្ត្រីរាជការស៊ីវិលដែលសកម្ម ដែលមានចំនួនប្រហែល១៨០០០០នាក់។ ដោយឡែកបុគ្គលិករបស់ប៉ូលីស និងកងកំលាំងប្រដាប់អាវុធមិនត្រូវបានគ្របដណ្តប់ដោយមូលនិធិសន្តិសុខសង្គមជាតិសម្រាប់មន្ត្រីរាជការ(NSSF-C) ប៉ុន្តែដោយមូលនិធិជាតិសម្រាប់អតីតយុទ្ធជន([59])។ មន្ត្រីរាជការស៊ីវិលទទួលបានប្រាក់សោធន ដែលរួមមានរបួសការងារ, ជំនួយបុណ្យសព និងការសំរាកលំហែមាតុភាព និងអ្នកជំងឺទទួលបានកម្រៃហិរញ្ញប្បទានពីថវិការបស់រដ្ឋាភិបាល។

ជាសរុប រាជរដ្ឋាភិបាលបានសម្រេចបានច្រើន ក្នុងការបង្កើតជាស្ថាប័នទាក់ទងនឹងប្រព័ន្ធសន្តិសុខសង្គម ប៉ុន្តែដំណើរការនេះនៅមានភាពស្មុគ្រស្មាញ និងការផ្តល់សេវានៅមានភាពមិនច្បាស់លាស់។

## IV. **សន្និដ្ឋាន**

រាជរដ្ឋាភិបាលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា បានអនុវត្ត និងបំពេញនូវកម្មវិធីនយោបាយរបស់ខ្លួន ដែលជាការសន្យាមានសូចនាករច្បាស់លាស់សំខាន់ៗចំនួនប្រាំ ក្នុងចំណោម១០សូចនាករច្បាស់លាស់ដូចជា៖

---

([57]) យោងតាមគេហទំព័របេឡាជាតិរបបសន្តិសុខសង្គមចុះផ្សាយដើមឆ្នាំ២០១៣៖ http://www.nssf.gov.kh/

([58]) http://www.social-protection.org/gimi/gess/ShowProjectSpeWiki.do?wid=895

([59]) http://www.social-protection.org/gimi/gess/ShowProjectSpeWiki.do?wid=895

- រាជរដ្ឋាភិបាលនឹងខិតខំបង្កើនផលិតផលសរុបសម្រាប់មនុស្សម្នាក់ ឲ្យកើនឡើងដល់ចំនួនប្រមាណ៨៧០ដុល្លារអាមេរិកក្នុងឆ្នាំ២០១៣។
- រាជរដ្ឋាភិបាល... កាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ឲ្យបានជាមធ្យមលើសពី១%ក្នុងមួយឆ្នាំ។
- រាជរដ្ឋភិបាល...បង្កើនប្រាក់បៀវត្សរ៍ជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធឲ្យបានយ៉ាងតិច ២០% ក្នុងមួយឆ្នាំលើប្រាក់បៀវត្សរ៍មូលដ្ឋាន។
- រាជរដ្ឋភិបាល...បង្កើនផ្ទៃដីដោះមីនឲ្យដល់៤៥ 000 ហិកតានៅឆ្នាំ២០១០
- រាជរដ្ឋាភិបាលបន្តអភិវឌ្ឍន៍សមត្ថភាពផ្គត់ផ្គង់ទឹកស្អាត... ដោយខិតខំសម្រេចទិសដៅផ្គត់ផ្គង់ទឹកស្អាត ដល់ប្រជាជននៅជនបទឲ្យបានពី៤០ ទៅ៤៥% នៅឆ្នាំ២០១២។

  ដោយឡែក ការសន្យាដែលមានសូចនាករច្បាស់លាស់ចំនួនប្រាំទៀត រាជរដ្ឋាភិបាលដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា ពុំទាន់សម្រេចបានពេញលេញ(សម្រេចបានខ្លះៗ) ដូចការសន្យានៅឡើយនោះទេមានដូចជា៖

- រាជរដ្ឋាភិបាល...ខិតខំសំរេចនូវកំណើនសេដ្ឋកិច្ចពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១៣ ឱ្យបានជាមធ្យម ៧%ក្នុងមួយឆ្នាំ។
- រាជរដ្ឋាភិបាល...ខិតខំរក្សាកំណើនភ្ញៀវទេសចរបរទេសប្រមាណ២០%ជារៀងរាល់ឆ្នាំ។
- រាជរដ្ឋាភិបាល...ជំរុញឲ្យកុមារទូទៅបញ្ចប់ការសិក្សាថ្នាក់បឋមសិក្សានៅឆ្នាំ ២០១០...។
- រាជរដ្ឋាភិបាល...ជំរុញឲ្យកុមារទូទៅបញ្ចប់ការសិក្សាកម្រិតមូលដ្ឋាន៩ឆ្នាំ នៅឆ្នាំ២០១៥...។
- រាជរដ្ឋាភិបាលនឹងរៀបចំបង្កើតប្រព័ន្ធសន្តិសុខសង្គម សម្រាប់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ កម្មករ និងនិយោជិត និងស្រទាប់ប្រជាជនផ្សេងៗ...។

# របាយការណ៍សង្ខេប

# ការអង្កេត និងការវាយតម្លៃលើការអនុវត្តកម្មវិធីនយោបាយដែលមានសូចនាករច្បាស់លាស់របស់រាជរដ្ឋាភិបាល និងមន្ត្រីជាប់ឆ្នោតនីតិកាលទី៤

មតិក្នុងរបាយការណ៍នេះមិនឆ្លុះបញ្ចាំងពីជំហររបស់ម្ចាស់ជំនួយ និងដៃគូឡើយ។

ឧបត្ថមដោយ៖

**Supported by:**

European Union

អាសយដ្ឋាន /Address ស្នាក់ការៈផ្ទះលេខ១៣៨ ផ្លូវលេខ១២២ ខណ្ឌទួលគោក រាជធានីភ្នំពេញ

P.O.Box 1145, CCC Box439 Phone: (023) 884 150

Fax: (855-23) 855 745